ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
អគ្គនាយកដ្ឋានឧស្សាហកម្ម
នាយកដ្ឋានវាយតម្លៃទទួលស្គាល់
Ministry of Industry & Handicraft
General Department of Industry
Department of Accreditaion
"NAFP-Cambodian Accreditation National Council"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

លេខ No. ០៥៥ ន.វ.ស

# <u>សេចក្តីជូនដំណឹង</u>
# ស្តីពីការចុះបញ្ជីអ្នកជំនាញវាយតម្លៃទទួលស្គាល់

ក្រោយពីបានទទួលការឯកភាពជំខ្ពង់ខ្ពស់ពីឯកឧត្តមទេសរដ្ឋមន្ត្រីចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ នាយកដ្ឋានវាយតម្លៃទទួលស្គាល់ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្មសូមគោរពជូន និងជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា មេត្តាជ្រាបថា៖ ៖ នាយកដ្ឋានវាយតម្លៃទទួលស្គាល់នឹងដំណើរការការងារចុះបញ្ជីវាយតម្លៃទទួលស្គាល់ និងការងារវាយតម្លៃទទួលស្គាល់ដល់អង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត អធិការកិច្ច និងសេវាកម្មនានា ដោយនាយកដ្ឋានក៏ដូចជាក្រសួងត្រូវការអ្នកជំនាញច្រើនផ្នែកតាមតម្រូវការនៃការងារវាយតម្លៃទទួលស្គាល់ ដើម្បីមកចូលរួមធ្វើការងារវាយតម្លៃទទួលស្គាល់ទៅតាមរយៈពេលខ្លីៗដែលចាំបាច់ ដោយត្រូវចុះកិច្ចសន្យាជាមួយនាយកដ្ឋានវាយតម្លៃទទួលស្គាល់ដោយឡែកក្នុងរយៈពេលខ្លីនៃការធ្វើ Assessment តែប៉ុណ្ណោះ។ តាមការចាំបាច់នេះទើបនាយកដ្ឋានស្នើសុំអញ្ជើញអ្នកជំនាញក្នុង និងក្រៅក្រសួង-ស្ថាប័ននានា និង Assessor ក្រៅប្រទេស ដែលមានជំនាញ និងបទពិសោធន៍ច្បាស់លាស់លើគ្រប់ផ្នែកនៃវិជ្ជាជីវៈ មកចុះបញ្ជីដើម្បីត្រៀមបណ្តុះបណ្តាលឲ្យក្លាយជាអ្នកជំនាញវាយតម្លៃទទួលស្គាល់ (Assessor) កម្រិតជាតិ និងអន្តរជាតិ។ ក្រោយពីឆ្លងវគ្គបណ្តុះបណ្តាលនឹងក្លាយជា Assessor ជាតិ និងអន្តរជាតិ ពួកគាត់នឹងត្រូវបានទទួលការអញ្ជើញមកចុះកិច្ចសន្យាតាមតម្រូវការនៃក្រុមជំនាញ ដើម្បីចុះធ្វើការវាយតម្លៃទទួលស្គាល់ដល់អង្គភាពវាយតម្លៃភាពអនុលោមនៅទូទាំងប្រទេស ឬបរទេស។ បន្ថែមពីលើនេះទៀតពួកគាត់នឹងទទួលបាននូវប្រាក់កម្រៃទៅតាមទំហំនៃការងារ ព្រមទាំងបទពិសោធន៍ជាច្រើនពីការចុះបំពេញការងារក្នុងតួនាទីជាអ្នកជំនាញវាយតម្លៃទទួលស្គាល់កម្រិតជាតិ និងអន្តរជាតិ។

អាស្រ័យដូចបានគោរព និងជម្រាបជូនខាងលើ សូមឯកឧត្តម លោក លោកស្រី នាងកញ្ញា មេត្តាអញ្ជើញមកចុះបញ្ជីអ្នកជំនាញវាយតម្លៃទទួលស្គាល់ដោយឥតគិតកម្រៃ នៅនាយកដ្ឋានវាយតម្លៃទទួលស្គាល់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ។

សូមឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងដ៏ស្មោះ អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៤
**ប្រធាននាយកដ្ឋាន**

**ជៀន សេងគង់**

ព័ត៌មានបន្ថែមសូមទាក់ទងតាមលេខទូរស័ព្ទ:

- 017 363536
- 092 375363, 093 585852

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)-១៧-៣៦៣៥៣៦ ទូរសារ: (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Kingdom of Cambodia, Phone: (855)-17-363536, Fax: (855)-23-428263